**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣២ សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាប

----------

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ព្រំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម **ធីយ រឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម **ប៊ុន សម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម **ស៊ូ ភិរិន្ទ** | អភិបាលខេត្តសៀមរាប | សមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម **ចន្ទ តុងអ៊ីវ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |
| ៦-ឯកឧត្តម **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧-ឯកឧត្តម **ផង់ សារ៉ែត** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨-ឯកឧត្តម **វស់ ហ៊ីន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៩-ឯកឧត្តម **លី ប្រុស** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០-ឯកឧត្តម **សួង ម៉េងគា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ១១-ឯកឧត្តម **វត្ថី សារិន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២-ឯកឧត្តម **ហាក់ សេខលី** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣-ឯកឧត្តម **វស់ សមិយ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៤-ឯកឧត្តម **លឹម ស៊ីដេនីន** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥-លោកជំទាវ **ស៊ាន អារុន** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |

**ប្រការ ២ .-**

គណៈកម្មការរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំនៅខេត្តសៀមរាប មានមុខងារ និងភារកិច្ចដូចតទៅ :

-ធ្វើការសិក្សាលើសំណើ និងគម្រោងការរបស់ក្រុមហ៊ុន **ជេ និង អ** អាហ៍រ៉ណេ នីហ៍រ៉ណេ និងសំណង់ ក្នុងការរៀបចំស្ថាបនាមណ្ឌលរដ្ឋបាលប្រមូលផ្តុំមួយ ដែលរួមមានអគាររដ្ឋបាលចំណុះសាលាខេត្ត អគាររដ្ឋបាលចំណុះមន្ទីរពាក់ព័ន្ធទាំងអស់ក្នុងខេត្ត និងហេដ្ឋារចនាសម្ព័ន្ធនានា បម្រើឱ្យកិច្ចការរដ្ឋបាលដែលមានទីតាំងនៅឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ស្ថិតតាមដងផ្លូវជាតិលេខ ៦ ក្បែរបុរី **សៀង ណាំ** ជាថ្នូរនិងការប្រគល់ទីតាំងរដ្ឋបាលចំណុះសាលាខេត្ត និងទីតាំងរដ្ឋបាលចំណុះមន្ទីរពាក់ព័ន្ធទាំងអស់ក្នុងខេត្តសៀមរាបជូនសាមីក្រុមហ៊ុនវិញ

-ចុះសិក្សា ពិនិត្យស្រាវជ្រាវដល់មូលដ្ឋានខេត្តសៀមរាប និងធ្វើការវាយតម្លៃលើគ្រប់ទិដ្ឋភាពនៃទីតាំងរដ្ឋបាលចាស់ទាំងអស់នៅទីរួមខេត្តសៀមរាប ទីតាំងភូមិសាស្ត្រថ្មី និងគម្រោងការជាក់ស្តែង ដែលត្រូវរៀបចំមណ្ឌលរដ្ឋបាលប្រមូលផ្តុំរបស់សាមីក្រុមហ៊ុននេះ

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារនេះ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ .-**

គណៈកម្មការនេះ មានសិទ្ធិបង្កើតក្រុមការងារមួយជាជំនួយការ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីសម្រួលការងារ ។

**ប្រការ ៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តសៀមរាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com